**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :............០៨៦/២១.............**ក.ប**/ប្រ.ក.ម.ហ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតគណៈកម្មការប្រឹក្សាយោបល់ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវិធីក្នុងតំបន់អាស៊ាន

| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
|---|---|
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **ក្រសួងកិច្ចការនារី** |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន



*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើត "**គណៈកម្មការប្រឹក្សាយោបល់ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវិធីក្នុងតំបន់អាស៊ាន**" ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហ៊ី ឌុន្សី** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សហប្រធាន |
| ២. លោកជំទាវ | **ហ៊ី សាមិត្ត** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សហប្រធាន |
| ៣. លោកជំទាវ | **សួស រដ្ឋាធី** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៤. លោកជំទាវ | **ឡុង សុផល្លី** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥. ឯកឧត្តម | **សេង សក្ដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦. លោកជំទាវ | **ញាណា សុមិត្រា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី | សមាជិកា |
| ៧. ឯកឧត្តម | **រឿន រិទ្ធិរ័ត្ន** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៨. ឯកឧត្តម | **ឈ្លោក ដារ៉ា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៩. លោក | **ជួប ណារ៉ាត់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០. លោក | **ឡៀម និត្យាកោមល** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១. លោក | **ផុន ពុធបុរី** | ប្រធាននាយកដ្ឋានការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារី | សមាជិក |
| ១២. លោកស្រី | **ឈី រដ្ឋា** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកិច្ចការនារី | សមាជិកា |
| ១៣. លោក | **អ៊ុច បូរី** | អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានកិច្ចការ សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសង្គម-វប្បធម៌ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤. លោក | **ហាយ ចាន់ថេង** | អនុប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥. លោក | **អ៊ិត រ៉ាឌុច** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

១៦. កញ្ញា **កេត សារ័ត្ន** អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់
នៃក្រសួងកិច្ចការនារី សមាជិក

១៧. លោក **ឆន់ សម្បត្តិ** អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៨. លោក **ឃួន សុវណ្ណារ៉ា** អនុប្រធានផ្នែកផែនការ និងសហប្រតិបត្តិការ
នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៩. លោក **ឈៅ លីន** នាយការិយាល័យប្រឆាំងការជួញដូរមនុស្សឆ្លងដែន
នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន
នៃក្រសួងមហាផ្ទៃ សមាជិក

២០. លោកស្រី **ជាង មុយឆាង** ប្រធានការិយាល័យអាស៊ាន
នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិកា

២១. លោកស្រី **ស៊ីន ម៉ូនិច** ប្រធានការិយាល័យទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ
នៃនាយកដ្ឋានការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារី សមាជិកា

២២. លោក **ស៊ុំ វណ្ណារ័ត្ន** ប្រធានការិយាល័យផ្នែកច្បាប់នៃក្រសួងកិច្ចការនារី សមាជិក

២៣. លោក **ឈាង សារៈបញ្ញា** អនុប្រធានការិយាល័យ
នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៤. លោក **នោ ចន្ទួល** អនុប្រធានការិយាល័យទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ
នៃក្រសួងកិច្ចការនារី សមាជិក

២៥. លោកស្រី **អេង សុភាព** អគ្គលេខាធិការសហព័ន្ធនិយោជក
និងសមាគមពាណិជ្ជកម្ពុជា (CAMFEBA) សមាជិកា

២៦. លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា សមាជិកា

២៧. លោក **អន ម៉ិនហាក់** ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា សមាជិក

២៨. លោក **នាក់ ហេង** ប្រធានសមាគមដឹកជញ្ជូន និងការងារក្រៅប្រព័ន្ធ ស.ជ.ក.ប សមាជិក

២៩. លោកស្រី **អ៊ូ ទេពផល្លីន** ប្រធាននៃសហព័ន្ធសហជីពកម្មករចំណីអាហារ
និងសេវាកម្មកម្ពុជា សមាជិកា

៣០. លោក **ណៃ សុខចាសនា** អនុប្រធានប្រចាំការនៃសហភាពសហជីពកម្ពុជា សមាជិក

៣១. លោកស្រី **Pauline Tamesis** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា សមាជិកា

៣២. លោក **Frank Viault** អគ្គទីប្រឹក្សា-ប្រធានផ្នែកកិច្ចសហប្រតិបត្តិការប្រតិភូ
នៃសហភាពអឺរ៉ុបប្រចាំកម្ពុជា សមាជិក

| | | | |
|---|---|---|---|
| ៣៣. លោក | **Graeme Buckley** | នាយកប្រចាំប្រទេស ថៃ កម្ពុជា និង ឡាវ នៃអង្គការអន្តរជាតិខាងការងារ (ILO) | សមាជិក |
| ៣៤. លោកស្រី | **Sarah Knibbs** | ទីប្រឹក្សាជាន់ខ្ពស់ និង អនុប្រធានស្តីទីប្រចាំតំបន់ អាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិក នៃអង្គការ UN Women | សមាជិកា |
| ៣៥. លោកស្រី | **Agata Nieboj** | មន្ត្រីកម្មវិធីនៃប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា | សមាជិកា |
| ៣៦. កញ្ញា | **Rebecca Miller** | អ្នកសម្របសម្រួលថ្នាក់តំបន់ផ្នែកជួញដូរមនុស្ស និងការរត់ពន្ធមនុស្សចំណាកស្រុកនៃការិយាល័យ ប្រចាំតំបន់របស់ UNODC ប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក, ទីក្រុងបាងកក | សមាជិកា |
| ៣៧. លោក | **Barry Jessen** | ប្រធានកម្មវិធីនៃអង្គការ Samaritan's Purse | សមាជិក |
| ៣៨. លោក | **ម៉ុត សារណា** | នាយកប្រចាំប្រទេសនៃអង្គការ CARE International Cambodia | សមាជិក |
| ៣៩. លោក | **សៀង ម៉េង** | ប្រធានស្តីទីអង្គការ Winrock International | សមាជិក |
| ៤០. លោក | **ឃុំ សុខចា** | ប្រធានអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី | សមាជិក |
| ៤១. លោកស្រី | **ម៉ុក បញ្ញាទិចិត្រ** | នាយកប្រតិបត្តិអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ | សមាជិកា |
| ៤២. លោកស្រី | **រស់ សុភាព** | នាយកប្រតិបត្តិនៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) | សមាជិកា |
| ៤៣. លោកស្រី | **ទ្រី សុយហៀង** | នាយកប្រតិបត្តិនៃអង្គការនារីដើម្បីសន្តិភាព | សមាជិកា |

**ប្រការ២ ._**

គណៈកម្មការមានភារកិច្ចដូចតទៅ៖

- ផ្តល់ការណែនាំកម្រិតបច្ចេកទេស យុទ្ធសាស្ត្រ និងអភិបាលកិច្ចដល់គម្រោងសុវត្ថិភាព និងយុត្តិធម៌សម្រាប់ពលករទេសន្តរប្រវេសន៍នៃកម្មវិធីក្នុងតំបន់អាស៊ាន (SAFE & FAIR) នៅកម្ពុជា និងធានាឱ្យគម្រោងនេះអនុវត្តទៅបានដោយស្របទៅនឹងគោលនយោបាយ ក្របខណ្ឌជាតិ និងសកម្មភាពអាទិភាពនៃព្រះរាជាណាចក្រកម្ពុជា
- តម្រង់ទិស ផ្តល់ការណែនាំលើផែនការ និងការអនុវត្តសកម្មភាពនៃកម្មវិធីសុវត្ថិភាព និងយុត្តិធម៌
- កំណត់ និងផ្តល់សុពលភាពដល់សកម្មភាពអាទិភាព ផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិ បទប្បញ្ញត្តិជាតិ ក្របខណ្ឌជាតិ គោលនយោបាយអន្តរជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងបទប្បញ្ញត្តិតំបន់និងអន្តរជាតិ និងបញ្ហាដែលលេចឡើងថ្មីទាក់ទងនឹងពលករទេសន្តរប្រវេសន៍ជាស្ត្រី
- ពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃអំពីវឌ្ឍនភាព និងការងារដែលសម្រេចបាននៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ

- ពិនិត្យ និងពិភាក្សាលើការអនុវត្តល្អៗ បញ្ហាប្រឈម និងរិះរកដំណោះស្រាយ
- ពិនិត្យ និងផ្តល់យោបល់លើការស្រាវជ្រាវ និងឯកសារបោះពុម្ពផ្សេងៗ
- អនុប្រធាន សមាជិក និងសមាជិកានៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំប្រចាំឆមាស ឬតាមការកំណត់របស់សហប្រធាន។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៧រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រី**
**ក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ